ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

# គោលការណ៍ណែនាំ
# ស្តីពី
# ការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រី នៅកម្ពុជា

រៀបចំដោយៈ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ឧបត្ថម្ភដោយៈ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

កក្កដា ២០១៥

## គោលការណ៍ណែនាំស្តីពីការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា

បោះពុម្ពផ្សាយ៖ ខែកក្កដា ឆ្នាំ២០១៥

បោះពុម្ពផ្សាយដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

អាសយដ្ឋាន៖ លេខ:៥៤ បេអេហ្វ៤៩/ ផ្លូវ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក

រាជធានីភ្នំពេញ ទូរស័ព្ទលេខ (០២៣) ៨៨៣ ៤២៧ ទូរសារលេខ (០២៣) ៨៨៣ ៤២៧

© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


គោលការណ៍ណែអំពីការសិក្សាស្រាវជ្រាវ... ១
០១ កំណត់ចំណាំដែលមានប្រយោជន៍សម្រាប់គ្រូបង្គោល ២
០២ ការសាយភាយអំពីចលនាសហគមន៍កសិកម្ម ១០
០៣ ប្រវត្តិរបស់ចលនាសហគមន៍កសិកម្ម ១១
០៤ សម្ព័ន្ធសហគមន៍អន្តរជាតិ [ICA] និងគោលការណ៍គ្រឹះសហគមន៍ ១៧
០៥ ទម្រង់សហគមន៍កសិកម្ម ២៨
០៦ រចនាសម្ព័ន្ធចាត់តាំងនៃសហគមន៍កសិកម្ម ៣១
០៧ ការរៀបចំសហគមន៍កសិកម្ម ៣៣
០៨ ច្បាប់ វិធាន បទបញ្ជាផ្ទៃក្នុង/និងលក្ខន្តិកៈសហគមន៍កសិកម្ម ៣៥
០៩ ហេតុអ្វីត្រូវចូលជាសមាជិកសហគមន៍កសិកម្ម? ៤០
១០ សិទ្ធិ និងកាតព្វកិច្ចរបស់សហគមន៍កសិកម្ម ៤១
១១ សិទ្ធិ និងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម ៤៣
១២ មហាសន្និបាតសហគមន៍កសិកម្ម ៤៤
១៣ សិទ្ធិ និងភារកិច្ចសមាជិកក្រុមប្រឹក្សាភិបាល ៤៦
១៤ គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម ៤៩
១៥ សិទ្ធិ និងភារកិច្ចរបស់អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងទៀត ៥០
១៦ សៀវភៅស្តីពីសហគមន៍កសិកម្ម ៥២
១៧ ការបង្កើតដើមទុននៅក្នុងសហគមន៍កសិកម្ម ៥៤
១៨ សេវាកម្មផ្តល់ដោយសហគមន៍កសិកម្ម ៥៥
១៩ សេវាកម្មឥណទានផ្តល់ដោយសហគមន៍កសិកម្ម ៥៧

២០ ការធ្វើសវនកម្មលើសហគមន៍កសិកម្ម .................................................................... ៦០

២១ ការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់សហគមន៍កសិកម្ម.............................................. ៦១

២២ ការលើកកម្ពស់ការគ្រប់គ្រងមុខរបររបស់សហគមន៍កសិកម្ម....................................... ៦២

២៣ ចំណុចពិសេសសម្រាប់ការពិចារណា.........................................................................៦៣

២៤ សេចក្តីសង្ខេបនៃការពិភាក្សា................................................................................. ៦៦

ឧបសម្ព័ន្ធ ១ ចលនាសហគមន៍កសិកម្មនៅកម្ពុជា ............................................................. ៦៩

អំពីអ្នកនិពន្ធ....................................................................................................................៧៤

## គោលការណ៍ណែនាំអំពីការសិក្សាស្រាវជ្រាវ

០១ “**គោលការណ៍ណែនាំអំពី ការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិក សហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា**” នេះ ត្រូវបានរៀបរៀងឡើងក្នុងគោលបំណងផ្តល់កម្មវិធីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លីដល់សមាជិក និងមន្ត្រីសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

០២ សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលនេះ គឺផ្អែកលើបទបញ្ញត្តិនៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទពិសោធន៍របស់មន្ត្រីផ្សព្វផ្សាយសហគមន៍កសិកម្មនៅក្នុងវិស័យនេះ ព្រមទាំងមកពីបណ្តាប្រទេសដែលសហគមន៍កសិកម្មទទួលបានជោគជ័យខ្លាំងផងដែរ។ ច្បាប់បច្ចុប្បន្នទំនងជាមានការតាក់តែងបានល្អ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែការអនុវត្តរបស់វាក្នុងវិស័យនេះ ពិតជាចាំបាច់ត្រូវការការកែលម្អបន្ថែមទៀត។ ទោះបីជាបទបញ្ញត្តិ និងការគាំពារទាំងអស់ ត្រូវបានបង្កើតឡើងនៅក្នុងអត្ថបទផ្សេងៗនៃច្បាប់នេះក្តីក៏ការអនុវត្តរបស់វាឈានទៅរកលទ្ធផលជោគជ័យ និងពិតប្រាកដ ត្រូវពឹងផ្អែកលើការប៉ិនប្រសប់របស់មហាសន្និបាត និងក្រុមប្រឹក្សាភិបាល។ មិនមែនអ្វីគ្រប់យ៉ាងសុទ្ធតែអាចសរសេរចូលទៅក្នុងច្បាប់នេះបានទេ ដោយបញ្ហាជាច្រើននៅតែត្រូវការការបកស្រាយផ្អែកទៅលើកាលៈទេសៈបច្ចុប្បន្ន។នោះជាមូលហេតុដែលច្បាប់ទាំងអស់នៅក្នុងពិភពលោក ផ្តល់ឱកាសសម្រាប់ការធ្វើវិសោធនកម្មនិងការកែលម្អ។

០៣ តាមការរំពឹងទុកថា គ្រូបង្គោលនិងមន្ត្រីផ្សព្វផ្សាយសហគមន៍កសិកម្មក្នុងប្រទេសកម្ពុជានឹងធ្វើការកត់សម្គាល់ផ្នែកផ្សេងៗនៃសៀវភៅណែនាំនេះ ដើម្បីដោះស្រាយប្រធានបទនេះឱ្យបានសមស្រប។ ជំពូកពិសេសមួយស្តីពី ‘កំណត់សម្គាល់មានប្រយោជន៍សម្រាប់គ្រូបង្គោល’ នេះ ត្រូវបានបន្ថែមដើម្បីផ្តល់ព័ត៌មានសារតារដល់គ្រូបង្គោល។ ជំពូកនេះកត់សម្គាល់ការអភិវឌ្ឍក្នុងវិស័យនេះនៅក្នុងប្រទេសផ្សេងទៀតៗផងដែរ។

០៤ ដោយមានការរំពឹងទុកថា គ្រូបង្គោលនឹងផ្តល់កម្មវិធីបណ្តុះបណ្តាលដោយទាញយកអត្ថប្រយោជន៍ពីពត៌មានផ្តល់ឱ្យនៅក្នុងសៀវភៅណែនាំនេះ ព្រមទាំងបទពិសោធន៍របស់សហគមន៍កសិកម្មដែលមានស្រាប់ផងដែរ។ នៅចុងបញ្ចប់នៃជំពូកនេះមាន "ចំណុចសម្រាប់ការពិភាក្សា”ផងដែរ។ គ្រូបង្គោលអាចប្រើប្រាស់ចំណុចទាំងនេះបានដើម្បីសង្ខេបជំពូក ព្រមទាំងដើម្បីពិនិត្យមើលការយល់ដឹងរបស់សិក្ខាកាមលើបញ្ហានេះផងដែរ។

កំណត់សម្គាល់មួយស្តីពីចលនាសហគមន៍កសិកម្មនៅកម្ពុជា ត្រូវបានដាក់ជា **ឧបសម្ព័ន្ធ ១**។

---

# ជំពូកទី ០១
## កំណាត់ចំណាំដែលមានប្រយោជន៍សម្រាប់គ្រូបង្គោល

តាមការរំពឹងទុកថា គ្រូបង្គោលដែលតម្រូវឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាល នឹងដឹងពីទិដ្ឋភាពសំខាន់ៗផ្សេងៗនៃការអភិវឌ្ឍរបស់សហគមន៍កសិកម្ម។ កំណត់សម្គាល់ទាំងនេះក៏នឹងនាំយកនូវបទពិសោធន៍របស់សហគមន៍កសិកម្មនៅក្នុងប្រទេសផ្សេងទៀតផងដែរ។ មានកំណត់សម្គាល់មានប្រយោជន៍មួយចំនួនសម្រាប់គោលការណ៍ណែនាំរបស់គ្រូបង្គោលត្រូវបានផ្តល់ឱ្យដូចខាងក្រោម៖

រចនាសម្ព័ន្ធរបស់សហគមន៍កសិកម្មឈរលើសរសរស្តម្ភយ៉ាងរឹងមាំចំនួនបួន។ សរសរស្តម្ភទាំងនេះមានដូចជា៖ [i] ការចូលរួម [ii] អភិបាលកិច្ច [iii] តម្លាភាព និង [iv] សេវាកម្ម។ គោលការណ៍ទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងដែរនៅក្នុងគោលការណ៍ទាំងប្រាំពីរនៃសម្ព័ន្ធសហគមន៍អន្តរជាតិ ដែលមានការទទួលស្គាល់ជាសាកល។ ខណៈគោលការណ៍នៃសម្ព័ន្ធសហគមន៍អន្តរជាតិនេះសម្រាប់ណែនាំអំពីចលនារួមរបស់សហគមន៍កសិកម្ម គោលការណ៍ចំនួនបួនដូចបានរៀបរាប់ពីខាងលើ ជំរុញសហគមន៍កសិកម្មឆ្ពោះទៅការក្លាយខ្លួនជាស្ថាប័នមានប្រសិទ្ធភាពក្នុងការបម្រើសេវាកម្មដល់សមាជិករបស់ខ្លួន។ សម្រាប់គោលបំណងបញ្ជាក់ឱ្យកាន់តែច្បាស់ និងការយល់ដឹងកាន់តែប្រសើរ ចូរយើងពិភាក្សាគ្នាលើគោលការណ៍ទាំងបួននេះ៖

***[i] ការចូលរួម៖*** លក្ខខណ្ឌជាមូលដ្ឋានសម្រាប់សហគមន៍កសិកម្មទទួលបានភាពជោគជ័យ គឺការចូលរួមពីសមាជិកកសិករនៅក្នុងគ្រប់ប្រតិបត្តិការស្ថាប័ន និងមុខរបរ។ គ្មានសហគមន៍កសិកម្មណាអាចផ្តល់សេវាកម្មបានល្អបំផុតដោយគ្មានការចូលរួមពីសមាជិកឡើយ។ ការចូលរួមនៅទីនេះមានន័យថា ការចូលរួមរាល់កិច្ចប្រជុំ ការផ្តល់មុខតំណែងផ្សេងៗដោយស្ម័គ្រចិត្តតាមរយៈការបោះឆ្នោតជ្រើសតាំង ការធ្វើការរួមគ្នាដើម្បីភាពរីកចម្រើនរបស់សហគមន៍កសិកម្មពួកគេ ការសួរសំណួរ [អំពីរបាយការណ៍សវនកម្មប្រចាំឆ្នាំ និងកម្មវិធីការងារ ។ល។ អំឡុងពេលកិច្ចប្រជុំ ការលើកជាសំណូមពរអំឡុងពេលកិច្ចប្រជុំ និងក្រៅកិច្ចប្រជុំ ការទិញយក ការលក់ចេញផលិតផលទាំងអស់តាមរយៈសហគមន៍កសិកម្ម ហើយប្រសិនបើអ្នកទទួលយកប្រាក់កម្ចីពីសហគមន៍កសិកម្ម វាក្លាយជាការទទួលខុសត្រូវរបស់អ្នកក្នុងសងរម្លស់រហូតគ្រប់ចំនួន និងទាន់ពេលវេលាដើម្បីឱ្យសមាជិកទាំងអស់ផ្សេងទៀតអាចទាញយកអត្ថប្រយោជន៍ពីប្រាក់កម្ចីនេះ ការដាក់ប្រាក់បញ្ញើដោយស្ម័គ្រចិត្តក្នុងសហគមន៍កសិកម្ម ការទិញយករាល់ទិន្នផលកសិដ្ឋាន និងការអនុវត្តរបស់សហគមន៍កសិកម្ម ។ល។ ស្ថាប័នសហគមន៍កសិកម្មទាំងអស់នៅទូទាំងពិភពលោករីកចម្រើន និងទទួលបានជោគជ័យដោយឈរលើគោលការណ៍នៃការចូលរួម ហើយការចូលរួមត្រូវតែជាការស្ម័គ្រចិត្ត ឥតគិតថ្លៃ និងដោយគ្មានការគ្រោងទុក។ ការ